00899021

E281

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
12 / 04 / 2013
ម៉ោង (Time/Heure): 13:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣

**ជូនចំពោះ:** សហចៅក្រមស៊ើបអង្កេត

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២, លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ចម្លើយតបទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេត ដែលបានស្នើសុំកែប្រែចំណាត់ថ្នាក់ឯកសារមួយចំនួនក្នុងសំណុំរឿង ០០២ ទៅជាឯកសារសាធារណៈ

អង្គជំនុំជម្រះសាលាដំបូងសូមថ្លែងអំណរគុណដល់សហចៅក្រមស៊ើបអង្កេតចំពោះលិខិតចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ទាក់ទងនឹងបញ្ជីឯកសារមួយចំនួនដែលបានដាក់ក្នុងសំណុំរឿង ០០២ ដោយសហចៅក្រមស៊ើបអង្កេត ហើយដែលឯកសារទាំងនោះដំបូងឡើយត្រូវបានសហចៅក្រមស៊ើបអង្កេតចាត់ថ្នាក់ជាប្រភេទឯកសារសម្ងាត់ ហើយឥឡូវនេះសហចៅក្រមស៊ើបអង្កេតយល់ថា ឯកសារទាំងនោះអាចធ្វើចំណាត់ថ្នាក់ឡើងវិញជាប្រភេទឯកសារសារធារណៈដោយមិនចាំបាច់ធ្វើការកោសលុប។ អង្គជំនុំជម្រះបានធ្វើការពិនិត្យឡើងវិញនូវឯកសារទាំងនោះ ហើយយល់ស្របថា ឯកសារទាំងនោះគួរតែប្តូរចំណាត់ថ្នាក់ជាប្រភេទឯកសារសាធារណៈ ។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងរៀបចំផ្លាស់ប្តូរចំណាត់ថ្នាក់ឯកសារទាំងនោះជាប្រភេទឯកសារសាធារណៈ។